ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៣

# សេចក្តីជូនដំណឹង

## សវនាការរបស់អង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី១៨ និង ១៩ ខែកុម្ភៈ ឆ្នាំ ២០១៣

នៅក្នុងសេចក្តីសម្រេចចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូល នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) សម្រេចថាសេចក្តីសម្រេចកាលពីមុន របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការបំបែកសំណុំរឿង ០០២ ជាសវនាការតូចៗនោះ គឺគ្មានសុពលភាព។

ដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូងអាចដោះស្រាយបាននូវភាពមិនជាក់លាក់ក្នុងពេលបច្ចុប្បន្ននេះ ពាក់ព័ន្ធនឹងវិសាលភាពដែលអាចប្រមើលមើលបាន នៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ហើយដើម្បីកាត់បន្ថយជាអតិបរិមានូវការពន្យារពេលនៃសវនាការដែលកំពុងតែបន្តក្នុងសំណុំរឿង ០០២/០១ និងដើម្បីគោរពទៅតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូលផងដែរនោះ អង្គជំនុំជម្រះសាលាដំបូង បានកំណត់កាលបរិច្ឆេទបើកសវនាការដែលនឹងប្រព្រឹត្តទៅនៅថ្ងៃចន្ទ ទី ១៨ ខែ កុម្ភៈ និងថ្ងៃអង្គារ ទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣ ដែលក្នុងសវនាការនោះ ភាគីទាំងអស់នឹងអាចដាក់នូវសារណានានាពាក់ព័ន្ធទៅនឹងវិសាលភាពនៃការជំនុំជម្រះ។

សវនាការនឹងចាប់ផ្តើមនៅម៉ោង ៩ ព្រឹក ហើយសាធារណជន និងប្រព័ន្ធផ្សព្វផ្សាយត្រូវបានអនុញ្ញាតឲ្យចូលរួម។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃ: +៨៥៥(0)១២ ៤៨៨ ០២៣
ទូរស័ព្ទ: +៨៥៥ (0)២៣ ២១៩ ៨៤១ លេខបន្ត: ៦១៦៩
សារអេឡិចត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ: +៨៥៥ (0)១២ ៤៨៨ ១៥៦
សារអេឡិកត្រូនិក: neth.pheaktra@eccc.gov.kh